ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខៈ ៤៤៩ សណ១/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង និងខេត្តសៀមរាប**

**<u>កម្មវត្ថុ</u>** ÷ អំពីការគាំទ្រ និងសម្របសម្រួលដល់អង្គការបន្ទាយស្រី ដើម្បីអនុវត្តកម្មវិធី " ពង្រឹងអំណាចស្ត្រីជនបទនៅកម្ពុជា ដើម្បីនិរន្តរភាពសេដ្ឋកិច្ច និងកម្មវិធីស្ត្រីក្នុងវិស័យនយោបាយ " នៅក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាប។

**<u>យោង</u>** ÷ លិខិតរបស់អង្គការបន្ទាយស្រី ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន**ឯកឧត្តម** ជ្រាបថា អង្គការបន្ទាយស្រី បានធ្វើសំណើសុំការគាំទ្រ និងសម្របសម្រួលដល់អង្គការរបស់ខ្លួន ដើម្បីអនុវត្តកម្មវិធី " ពង្រឹងអំណាចស្ត្រីជនបទនៅកម្ពុជា ដើម្បីនិរន្តរភាពសេដ្ឋកិច្ច និងកម្មវិធីស្ត្រីក្នុងវិស័យនយោបាយ" នៅក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាប មកលេខាធិការដ្ឋាន គ.ជ.អ.ប ហើយលេខាធិការដ្ឋាន គ.ជ.អ.ប បានយល់ព្រមអនុញ្ញាតឱ្យអង្គការបន្ទាយស្រីអនុវត្តកម្មវិធីតាមការស្នើសុំ ធ្វើកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងពេលអនុវត្តការងារជាក់ស្តែង និងត្រូវអនុវត្តសកម្មភាពស្របតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។ សូមជម្រាបថា អង្គការបន្ទាយស្រី គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយធ្វើសកម្មភាពដើម្បីពង្រឹងសមត្ថភាពស្ត្រីក្នុងភាពជាអ្នកដឹកនាំគ្រប់លំដាប់ថ្នាក់ និងពង្រឹងការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន លើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិស្ត្រី ព្រមទាំងបញ្ឈប់អំពើហិង្សាផ្អែកយេនឌ័រ នៅក្នុងឃុំ សង្កាត់គោលដៅចំនួន០៨ នៃក្រុងបាត់ដំបង ស្រុកបវេល ខេត្តបាត់ដំបង និងឃុំគោលដៅចំនួន០៨ នៃស្រុកអង្គរធំ ស្រុកពួក ខេត្តសៀមរាប ដោយអនុវត្តកម្មវិធីរបស់ខ្លួនចាប់ពីដើមឆ្នាំ២០១៦ រហូតដល់ដំណាច់ឆ្នាំ២០១៨ ខាងមុខនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម**ឯកឧត្តម** ផ្តល់ការគាំទ្រនិងជួយសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យការអនុវត្តកម្មវិធីខាងលើ ទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ជ.ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**